CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 19 ខែមករា ឆ្នាំ 2021

ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងភ្នំពេញ, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយ ភ្លាមៗ

# សាលាក្រុង បើកដំណើរការ គ្លីនិកចាក់ថ្នាំបង្ការ ទ្រង់ទ្រាយធំ នៅមជ្ឈមណ្ឌលសន្និសីទឡុងប៊ិច

*សាលាក្រុង ក៏បើកដំណើរការ VaxLB ដែលជាច្រក ថ្នាំបង្ការ COVID-19 ផងដែរ*

ឡុងប៊ិច, CA ៖ សាលាក្រុងឡុងប៊ិច នឹងចាប់បើកដំណើរការ គ្លីនិកចាក់ថ្នាំបង្ការទ្រង់ទ្រាយធំ នៅមជ្ឈមណ្ឌលសន្និសីទ និងកំសាន្ត ឡុងប៊ិច សម្រាប់បុគ្គលិកសុខាភិបាល និងជនវ័យចាស់ ។ ត្រូវមានការណាត់ជួបទុកជាមុន ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Gar-cia) បានលើកឡើងថា «គ្លីនិកចាក់ថ្នាំបង្ការទ្រង់ទ្រាយធំថ្មីរបស់យើង នឹងពង្រីកសមត្ថភាពរបស់យើង ក្នុងការចាក់ថ្នាំបង្ការ ជូនប្រជាពលរដ្ឋ ក្នុងមួយថ្ងៃ បានច្រើនជាង ពីពេលមុនៗទៀត ។» «កម្មវិធីចាក់ថ្នាំបង្ការរបស់យើង បានកំពុងក្លាយទៅជា គំរូនៅទូទាំងរដ្ឋ បានយ៉ាងឆាប់រហ័ស ហើយយើងខ្ញុំមានមោទកភាព អំពីល្បឿន ដែលយើងដំណើរការ ពីក្រុមមួយទៅក្រុមមួយទៀត ។»

សាលាក្រុងឡុងប៊ិច បន្តចាត់ចែងថ្នាំបង្ការ នៅពេលមានថ្នាំបង្ការមកដល់ ។ ថ្នាំបង្ការត្រូវបានចាត់ចែង ទៅឱ្យបុគ្គលិកនៅតាមមន្ទីរពេទ្យ បុគ្គលិកសុខាភិបាលជួរមុខរបស់ក្រុង បុគ្គលិកមន្ទីរអគ្គីភ័យឡុងប៊ិច និង EMTs ។ កាលពីសប្តាហ៍មុន សាលាក្រុងបានចាប់ផ្តើម ដំណាក់កាល 1B នៃផែនការចាក់ថ្នាំបង្ការ នៅពេលនិយោជិតផ្សេងៗ ទៀត របស់ទីក្រុង ដែលចាំបាច់សម្រាប់កិច្ចខិតខំប្រឹងប្រែងសង្គ្រោះ ជាការឆ្លើយតបនឹង COVID-19 ទទួលបានការចាក់ថ្នាំបង្ការ ហើយការចាក់ថ្នាំបង្ការ ជូនជនវ័យចាស់ បានចាប់ផ្តើម នៅថ្ងៃទី 16 ខែមករា ។ មកទល់បច្ចុប្បន្ននេះ ថ្នាំបង្ការច្រើនជាង 21,000 ត្រូវបានចាត់ចែងផ្តល់ជូន នៅឡុងប៊ិច ។ ថ្នាំបង្ការទាំងអស់ត្រូវបានចាត់ចែងផ្តល់ជូន ដោយឥតគិតថ្លៃ ហើយមានផ្តល់ជូនដោយផ្ទាល់ ពីរដ្ឋាភិបាលសហព័ន្ធ ។

សព្វថ្ងៃនេះ នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស (នាយកដ្ឋានសុខាភិបាល) ក៏បានចាប់ដំណើរការ VaxLB ជាច្រកថ្នាំបង្ការថ្មីមួយ ដែលធ្វើដំណើរការស្វែងយល់ អំពី និងកំណត់កាលវិភាគចាក់ថ្នាំបង្ការ COVID-19 ឱ្យបានកាន់តែងាយស្រួល និងមានតម្លាភាពប្រសើរឡើងផងដែរ ។ ដោយចូលទៅ longbeach.gov/vaxLB យើងនឹងអាចចុះឈ្មោះ ដើម្បីអាចទទួលបាន ការជូនដំណឹង នៅពេលដល់វេនត្រូវចាក់ថ្នាំបង្ការ COVID-19 ។ វាក៏ផ្តល់ព័ត៌មានរួម

ទាំង ការណាត់ជួបបែបស្វ័យសេវា នៅពេលមានថ្នាំបង្ការអាចចាក់បាន សម្រាប់អ្នកដែលមានសិទ្ធិទទួលបានផងដែរ ។ គេហទំព័រ និងទម្រង់បែបបទចុះឈ្មោះមានផ្តល់ជូនជាភាសាអង់គ្លេស ភាសាអេស្ប៉ាញ ភាសាតាហ្គាឡុក និងភាសាខ្មែរ ។

ឃែលលី ខូឡូភី (Kelly Colopy) ប្រធាននាយកដ្ឋានសុខាភិបាល បានគូសបញ្ជាក់ថា «គោលដៅរបស់យើង គឺត្រូវចែកចាយថ្នាំបង្ការ ឱ្យបានប្រកបដោយយុត្តិធម៌ សមធម៌ និងឆាប់រហ័ស តាមដែលអាចធ្វើទៅបាន ។» « VaxLB នឹងធ្វើឱ្យដំណើរការចាក់ថ្នាំបង្ការ មានភាពងាយស្រួល ហើយអនុញ្ញាតឱ្យដំណើរការចាក់ថ្នាំបង្ការរបស់យើង ឈានទៅមុខបានដោយរលូន ។»

ការចែកចាយ និងការចាក់ថ្នាំបង្ការ គឺជាមុខងារធម្មតាមួយ របស់នាយកដ្ឋានសុខាភិបាល ។ ក្រុមការងារគ្រប់គ្រងករណីសង្គ្រោះបន្ទាន់ នៃផ្នែកសុខភាពសាធារណៈ និងអ្នកសម្របសម្រួលការចាក់ថ្នាំបង្ការ ទទួលបានការបណ្តុះបណ្តាល ហើយធ្វើការត្រៀមលក្ខណៈ ដើម្បីបំពេញការងារចាក់ថ្នាំបង្ការទ្រង់ទ្រាយធំ នៅឆ្នាំក្រោយៗទៀត ។ ក្នុងមួយឆ្នាំៗ រួមទាំងឆ្នាំនេះផង នាយកដ្ឋានសុខាភិបាលអនុវត្ត ប្រតិបត្តិនានា សម្រាប់ការចែកចាយថ្នាំបង្ការសង្គ្រោះបន្ទាន់ ដោយរៀបចំព្រឹត្តិការណ៍ចាក់ថ្នាំបង្ការទ្រង់ទ្រាយធំ នៅក្នុងទីក្រុង ក្នុងអំឡុងរដូវកាលគ្រុនផ្តាសាយធំ នៅពេលនាយកដ្ឋានផ្តល់ការចាក់ថ្នាំបង្ការគ្រុនផ្តាសាយធំ បែបបើកបរចូលចាក់ថ្នាំដោយឥតគិតថ្លៃ ។

កាលពីខែមុន សាលាក្រុងបានប្រកាស អំពីផែនការចែកចាយថ្នាំបង្ការ COVID-19 ប្រកបដោយសមធម៌ របស់ខ្លួន ។ នាយកដ្ឋានសុខាភិបាល កំពុងចាត់ចែងដំណើរការចែកចាយថ្នាំបង្ការ ហើយគោរពតាមគោលការណ៍ណែនាំ ពីមជ្ឈមណ្ឌលគ្រប់គ្រងជំងឺ (CDC) និងរដ្ឋកាលីហ្វ័រញ៉ា ។ សេចក្តីលំអិតបន្ថែមទៀត អំពីផែនការចាក់ថ្នាំបង្ការ របស់សាលាក្រុង អាចរកបាន នៅលើគេហទំព័រ របស់សាលាក្រុង ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #